ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៤៥៣ រប

ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០

សញ្ញាណរឿងក្តី៖ ប្តឹងសុំលែងលះ

សាលក្រមលេខ៖ ០៩៣ "ណ"

ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១

## ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជី

## សាលាដំបូងខេត្តកណ្តាល

សាលាដំបូងខេត្តកណ្តាល បានចេញសាលក្រមដែលមានគូភាគីដូចខាងក្រោម:

**-ដើមចោទ:** ឈ្មោះ [redacted] ហឿន ភេទស្រី កើតឆ្នាំ១៩៨២ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted]

មេធាវីតំណាងដោយអាណត្តិ៖ លោក [redacted] ។

**-ចុងចម្លើយ:** ឈ្មោះ [redacted] ប៉េងហ៊ន់ ភេទប្រុស កើតឆ្នាំ១៩៧៩ មានទីលំនៅភូមិ [redacted]

មេធាវីតំណាងដោយអាណត្តិ៖លោកស្រី [redacted] និងលោក [redacted] មានអាសយដ្ឋានការិយាល័យ [redacted] ។

**កម្មវត្ថុ:**

- ប្តឹងសុំទាមទារលែងលះពីប្តីឈ្មោះ [redacted] ប៉េងហ៊ន់
- សុំបែងចែកទ្រព្យសម្បត្តិរួម

## អង្គហេតុ និងចំណុចវិវាទ

១. ការពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទឈ្មោះ [redacted] ហឿន និងចុងចម្លើយឈ្មោះ [redacted] ប៉េងហ៊ន បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា តាមប្រពៃណី នៅដើមខែ០២ ឆ្នាំ២០១២ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាតាមច្បាប់នៅមុខមន្ត្រីអត្រានុកូលដ្ឋាននៅថ្ងៃទី២១ ខែ០២ ឆ្នាំ២០១២ ។ បន្ទាប់ពីបានរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយមិនមានកូនទេ ។ ចំពោះទ្រព្យសម្បត្តិរួមមាន: ដី និងផ្ទះមានទីតាំងស្ថិតនៅភូមិព្រៃសំរោង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ទំហំ ១០៥$m^2$ ម៉ូតូម៉ាកសង់ផលិតឆ្នាំ២០១២ មួយគ្រឿង ប្រាក់ចំនួន ១,០០០(មួយពាន់) ដុល្លាអាមេរិក មាស៣ជី ខ្សែកផ្កាកទិន៣ជី បំណុលចំនួន ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ។ ដោយសារការមានទំនាស់ជាញឹកញាប់ជាមួយនឹងគ្នា រហូតដល់មិនអាចរស់នៅជាមួយគ្នាទៀតបាន ទើបធ្វើឱ្យដើមចោទអស់មនោសញ្ចេតនា មិនអាចរស់នៅជាមួយគ្នាជាប្តីប្រពន្ធតទៅទៀតបាន ។ ដូច្នេះហើយ ទើបដើមចោទស្នើសុំឱ្យតុលាការសម្រេចអំពីការលែងលះ និងបែងចែកទ្រព្យសម្បត្តិ ។



Scanned with CamScanner

២. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

មូលហេតុដែលដើមចោទប្ដឹងសុំលែងលះពីចុងចម្លើយ ដោយសារតែការរស់នៅមិនចុះសម្រុងនឹងគ្នា ហើយចុងចម្លើយបានគំរាមប្រើអំពើហិង្សា ។

៣. សាលក្រមដែលទាមទារដោយដើមចោទ

- ប្ដឹងសុំទាមទារលែងលះពីប្ដីឈ្មោះ [redacted] ម៉ែងហ៊ន់
- សុំបែងចែកទ្រព្យសម្បត្តិរួម

៤. ការអះអាងរបស់ដើមចោទ

ដើមចោទឈ្មោះ [redacted] ហឿន បានអះអាងថា: ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នៅដើមខែកុម្ភៈ ឆ្នាំ២០១២ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ ។ បន្ទាប់ពីខ្លួនបានរៀបអាពាហ៍ពិពាហ៍រួច និងបានរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធរហូតដល់សព្វថ្ងៃ ហើយនៅក្នុងខែឧសភា ឆ្នាំ២០២០ ខ្លួនមានទំនាស់ជាញឹកញាប់ជាមួយនឹងគ្នារហូតដល់មិនអាចចុះសំរុងនឹងគ្នា ដោយសារឈ្មោះ [redacted] ប៉េងហ៊ន់ បានគំរាមប្រើអំពើហិង្សា ចង់កាប់សំលាប់ខ្លួន ។ ខ្លួនក៏បានសម្រេចចិត្តចុះចេញពីផ្ទះ ដោយខ្លាចឈ្មោះ [redacted] ប៉េងហ៊ន់ ប្រើអំពើហិង្សា និងសំលាប់រូបខ្លួន ។ ហើយការរួមរស់នេះ ខ្លួនមិនមានកូនទេ ហើយមានទ្រព្យសម្បត្តិរួមដូចជា៖

ក. ដី និងផ្ទះមានទីតាំងនៅភូមិព្រែកសំរោង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល ទំហំ ១០៥ម² មានកិច្ចសន្យាលក់ដី និងផ្ទេរសិទ្ធិកាន់កាប់លេខ ១៩៩ បជ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ចេញដោយមេឃុំដំណាក់អំពិល ។

ខ. ម៉ូតូម៉ាកសង់ផលិតឆ្នាំ២០១២ មួយគ្រឿងដែលខាងប្ដីជាអ្នកកាន់ប័ណ្ណកម្មសិទ្ធិ ។

គ. ប្រាក់ដុល្លា ១,០០០ (មួយពាន់) ដុល្លាអាមេរិក ។

ឃ. មាសចំនួន ០៣ (បី) ជី នៅខាងប្ដីខ្លះ និងប្រពន្ធខ្លះ ។

ង. ខ្សែករផ្កាកទីន មានតម្លៃជាប្រាក់ចំនួន ១,០០០,០០០ (មួយលាន) រៀល ។

មេធាវីឈ្មោះ [redacted] បានធ្វើសេចក្ដីថ្លែងការណ៍ថា: ចំពោះចំណុចទី១ នៃពាក្យបណ្ដឹង គឺខ្លួនមិនមានការថ្លែងការណ៍ទេ ។ ចំពោះចំណុចទី២ សុំបែងចែកទ្រព្យសម្បត្តិដូចក្នុងពាក្យបណ្ដឹងមានដី និងផ្ទះ និងទ្រព្យទាំងអស់សុំអោយបែងចែកជាពីរស្មើគ្នា ហើយចំពោះវិធីចែកសុំលក់រួចចែកលុយគ្នា ។

៥. ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] ប៉េងហ៊ន់ បានថ្លែងការណ៍ថា: ខ្លួនចង់រួមរស់ជាមួយដើមចោទវិញ ។ ចំពោះដី ផ្ទះ និងម៉ូតូ គឺខ្លួនទទួលស្គាល់ថាមានដូចការអះអាងរបស់ដើមចោទ តែចំពោះមាសមាន៣ជី នៅដើមចោទ ខ្សែកផ្កាកទីន នៅដើមចោទ ចំពោះលុយមានតែប្រាំពីររយដុល្លាអាមេរិក ហើយខ្លួនជំពាក់លុយគេថ្លៃប្រេង ប្រហែលប្រាំពីររយដុល្លារអាមេរិក។ខ្លួនមានម៉ូតូមួយទៀត ដែលខ្លួនបានអោយឪពុកម្ដាយក្មេកជិះ ជិះញៀនមៀសទម្ងន់មួយជីកន្លះ ។

ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ភាគីដើមចោទ

ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ភាគីចុងចម្លើយ

ក្រោពីថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. ក្រោយពីបានធ្វើការសាកសួរភាគីដើមចោទ ធ្វើការផ្សះផ្សា និងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងពិនិត្យភស្ដុតាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ តុលាការយល់ឃើញថា: គូភាគីពិតជាបានរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធ នឹងបានចុះសំបុត្រអាពាហ៍ពិពាហ៍ ពិតប្រាកដមែន ។

២. ដើមចោទអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាតទៅទៀតបាន ដោយសារតែការរស់នៅជាមួយគ្នាកន្លងមកពុំសូវចុះសម្រុងគ្នា ជាហេតុធ្វើឱ្យខ្លួនមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ដូច្នេះតុលាការចាត់ទុកថាកត្តាទាំងអស់ខាងលើនេះជាមូលហេតុនៃការលែងលះគ្នា តាមបញ្ញត្តិមាត្រា ៩៧៨ ចំណុច ១.ង នៃក្រមរដ្ឋប្បវេណី ។

៣. តាមការសួរដេញដោល នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់បញ្ជាក់ថា ភាគីដើមចោទ និងចុងចម្លើយ បានរៀបការតាំងពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ មកម្លេះ ហើយគូភាគីបានរួមរស់ជាមួយគ្នា មិនមានកូនទេ តែដោយការរស់នៅមិនចុះសម្រុងគ្នា ជាហេតុធ្វើឱ្យខ្លួនមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ។

៤. រឿងក្ដីនេះតុលាការអស់លទ្ធភាពក្នុងការផ្សះផ្សាហើយ ។

៥. ភស្តុតាងជាឯកសារដែលភាគីបានដាក់រួមមាន:

- សំបុត្រអាពាហ៍ពិពាហ៍លេខ ០៦ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១២ (មួយច្បាប់ថតចម្លង) ។
- កិច្ចសន្យាលក់ដី និងផ្ទេរសិទ្ធិកាន់កាប់លេខ ១៩៩ បជ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ រវាងឈ្មោះ [redacted] មួយលាភ និងឈ្មោះ [redacted] ឡៃ ទៅឱ្យឈ្មោះ [redacted] ម៉េងហ៊ន់ និងឈ្មោះ [redacted] ហឿន ដែលមានទំហំ ១០៥ ម៉ែត្រការ៉េ ។
- ប័ណ្ណសម្គាល់យានយន្តម៉ូតូមួយគ្រឿងម៉ាក HONDA DREAM125 ពាក់ស្លាកលេខ ភ្នំពេញ 1BM-9532 ពណ៌ខ្មៅ ។
- វិក័យបត្រចំនួនពីរសន្លឹក ។

៥. ផ្អែកតាមសំអាងហេតុខាងលើនេះ ការទាមទាររបស់ដើមចោទមានមូលដ្ឋានសំអាងត្រឹមត្រូវតាមច្បាប់ គប្បីតុលាការទទួលស្គាល់នូវការទាមទារនេះ ។

៦. ប្រាក់ប្រដាប់ក្តី អនុលោមតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១- ឱ្យដើមចោទឈ្មោះ [redacted] ហឿន លែងលះពីចុងចម្លើយឈ្មោះ [redacted] ម៉េងហ៊ន់ គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

២- ទ្រព្យសម្បត្តិរួមមាន៖

២.១- ដី និងផ្ទះទំហំ ១០៥ ម៉ែត្រការ៉េ ដែលមានកិច្ចសន្យាលក់ដី និងផ្ទេរសិទ្ធិកាន់កាប់លេខ ១៩៩ បជ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ត្រូវបែងចែកអោយទៅដើមចោទឈ្មោះ [redacted] ហឿន និងចុងចម្លើយឈ្មោះ [redacted] ម៉េងហ៊ន់ ជាពីរចំណែកស្មើគ្នា ដោយធ្វើការលក់ជាប្រាក់ ។

២.២- ម៉ូតូមួយគ្រឿងម៉ាក HONDA DREAM C125 ពាក់ស្លាកលេខភ្នំពេញ 1BM-9532 ត្រូវបែងចែកអោយទៅដើមចោទឈ្មោះ [redacted] ហឿន និងចុងចម្លើយឈ្មោះ [redacted] ម៉េងហ៊ន់ ជាពីរចំណែកស្មើគ្នា ដោយធ្វើការលក់ជាប្រាក់ ។

២.៣- ប្រាក់ដុល្លាចំនួន ៦០០ (ប្រាំមួយរយ) ដុល្លាអាមេរិក ត្រូវបែងចែកអោយទៅដើមចោទឈ្មោះ [redacted] ហឿន និងចុងចម្លើយឈ្មោះ [redacted] ម៉េងហ៊ន់ ជាពីរចំណែកស្មើគ្នា ។

២.៤- មាស់ចំនួន ០១ (មួយ) ជី ត្រូវបែងចែកទៅអោយដើមចោទឈ្មោះ [redacted] ហឿន និងចុងចម្លើយឈ្មោះ [redacted] ម៉េងហ៊ន់ ជាពីរចំណែកស្មើគ្នា ដោយធ្វើការលក់ជាប្រាក់ ។

២.៥- ប្រេងបាតចំនួន ០៤ (បួន) កេស ត្រូវបែងចែកអោយទៅដើមចោទឈ្មោះ [redacted] ហឿន និងចុងចម្លើយឈ្មោះ [redacted] ម៉េងហ៊ន់ ជាពីរចំណែកស្មើគ្នា ដោយធ្វើការលក់ជាប្រាក់ ។

២.៦- ចំពោះបំណុលរួមចំនួន ៧០០ (ប្រាំពីររយ) ដុល្លាអាមេរិក ត្រូវបែងចែកទៅអោយដើមចោទឈ្មោះ [redacted] ហឿន និងចុងចម្លើយឈ្មោះ [redacted] ម៉េងហ៊ន់ ទទួលខុសត្រូវសងម្នាក់ពាក់កណ្តាល ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

៤-សាលក្រមនេះទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ចំពោះមុខដើមចោទឈ្មោះ [redacted] ហឿន និងចំពោះមុខចុងចម្លើយ [redacted] ម៉េងហ៊ន់។

ទុកសិទ្ធិឱ្យគូភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃអង្គារ ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កណ្តាល, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

"បានចម្លងត្រឹមត្រូវតាមសាលក្រមដើម"



Scanned with CamScanner

ថ្ងៃសុក្រ ៤កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កណ្តាល, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១

បានឃើញ

ចៅក្រម

[redacted]

ក្រឡាបញ្ជី

[redacted]